**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

នាយកដ្ឋានព័ត៌មាន

# សេចក្ដីជូនព័ត៌មាន

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញទៅបំពេញទស្សនកិច្ចការងារផ្លូវការនៅប្រទេសជប៉ុន ចាប់ពីថ្ងៃ **ទី ០៦ ដល់ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៧** តបតាមការអញ្ជើញរបស់រដ្ឋាភិបាលជប៉ុន។

ឥស្សរជនដែលនឹងអញ្ជើញអមសម្ដេចតេជោនាយករដ្ឋមន្ត្រី ក្នុងដំណើរទស្សនកិច្ចនេះ រួមមានៈ

- ឯកឧត្ដម អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកឧត្ដម អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ
- ឯកឧត្ដម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍

និង សមាជិកនៃរាជរដ្ឋាភិបាលកម្ពុជាមួយចំនួនទៀត ។

ក្នុងអំឡុងពេលស្នាក់នៅប្រទេសជប៉ុន សម្ដេចតេជោនាយករដ្ឋមន្ត្រី នឹងចូលគាល់ព្រះអង្គម្ចាស់រាជទាយាទ ណារ៉ូហ៊ីតូ។

បន្ទាប់ពីចូលរួមក្នុងពិធីបដិសណ្ឋារកិច្ចផ្លូវការ សម្ដេចតេជោនាយករដ្ឋមន្ត្រី នឹងមានកិច្ចប្រជុំកំពូលជាមួយឯកឧត្ដម ស៊ីនហ្សូ អាបេ នាយករដ្ឋមន្ត្រីជប៉ុន និងធ្វើការប្រកាសព័ត៌មានរួមគ្នា ក្រោយពេលនាយករដ្ឋមន្ត្រីទាំងពីរ អញ្ជើញធ្វើជាអធិបតីក្នុងពិធីចុះហត្ថលេខាលើឯកសារចំនួនពីរ ស្ដីពីជំនួយជប៉ុនផ្ដល់មកកម្ពុជា ដូចខាងក្រោមៈ

១-ហិរញ្ញប្បទានឥតសំណង សំរាប់អនុវត្តគម្រោងធ្វើឱ្យប្រសើរឡើងវិញការការពារទឹកជំនន់ក្នុងរាជធានីភ្នំពេញ តំណាក់កាលទី៤ ដែលមានទឹកប្រាក់សរុបចំនួន ៣.៩៤៨ លានយ៉េន(ប្រមាណ៣៥លានដុល្លារអាមេរិក)និង

២-ឥណទានសម្បទាន សំរាប់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មីរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលមានទឹកប្រាក់សរុបចំនួន ២៣.៥០២ លានយ៉េន (ប្រមាណ២០៩ លានដុល្លារអាមេរិក)។

សម្ដេចតេជោ ក៏នឹងទទួលការចូលជួបសម្ដែងការគួរសម ដោយឡែកពីគ្នា ដោយតំណាងសមាគមមិត្តភាពសភាកម្ពុជា-ជប៉ុន សមាគមមិត្តភាពសភាជប៉ុន-មេគង្គ អង្គការពាណិជ្ជកម្មក្រៅប្រទេសរបស់ជប៉ុន ព្រមទាំងក្រុមហ៊ុនរបស់ជប៉ុនចំនួន៤ ផងដែរ។


អាសយដ្ឋាន: លេខ ៣ វិថី **សម្ដេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ឆ្លៀតក្នុងឱកាសដំណើរទស្សនកិច្ចការងារផ្លូវការនេះ  សម្តេចតេជោនាយករដ្ឋមន្ត្រី នឹងអញ្ជើញថ្លែងសុន្ទរកថាគន្លឹះក្នុងសិក្ខាសាលាស្តីពីឱកាសវិនិយោគនៅកម្ពុជា រៀបចំដោយសមាគមជប៉ុន-កម្ពុជា អញ្ជើញធ្វើទស្សនកិច្ចនៅរោងចក្រកែច្នៃកាកសំណល់ និងធ្វើដំណើរសាកល្បងតាមរថភ្លើងធុនស្រាលស្វ័យប្រវត្តិ។  សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏នឹងជួបសំណេះសំណាលជាមួយនិស្សិតកម្ពុជាដែលកំពុងសិក្សានៅជប៉ុន ផងដែរ។

ភ្នំពេញ ថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០១៧